# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបើកឆ្នាំសិក្សាថ្មីរបស់ទេវវិទ្យាល័យ
# ភ្នំពេញថ្មី ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩
# យើងចាក់ឫសនៅក្នុងដីនៃជីវិតរបស់ព្រះសហគមន៍

**អត្ថបទទី១៖ អេសាយ ២៥,៦-១០ក**

នៅលើភ្នំនោះ ព្រះអង្គនឹងដកស្បៃកាន់ទុក្ខ ចេញពីជាតិសាសន៍ទាំងប៉ុន្មាន ហើយក៏ដក វាំងននទុក្ខព្រួយចេញពី ប្រជាជាតិទាំងអស់ដែរ។ អស ២៥,៧

**ដំណឹងល្អ៖ ម៉ាថាយ ១៥,២៩-៣៧**

មានមហាជនច្រើនកុះករនាំគ្នាចូលមករកព្រះអង្គ ទាំងនាំមនុស្សខ្វិន មនុស្សខ្វាក់ មនុស្សពិការជើង មនុស្សគថ្លង់ និងអ្នកមានជំងឺឯទៀតៗមកជាមួយ។ គេដាក់អ្នកទាំងនោះនៅទៀបព្រះបាទាព្រះអង្គ ហើយព្រះអង្គប្រោសគេឲ្យបានជាទាំងអស់គ្នា។ មថ ១៥,៣០

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាថ្ងៃឱឡារិកសម្រាប់បើកឆ្នាំសិក្សាថ្មីនៅទេវវិទ្យាល័យ យើងមានអំណរសប្បាយ ហើយជាពេលវេលាដើម្បីនឹកឃើញដល់ជីវិតរបស់ព្រះសហគមន៍។ ទេវវិទ្យាល័យ ជាកន្លែងមួយពិសេសដើម្បីអប់រំកូនសិស្សរបស់លោកអភិបាល ដែលកំពុងត្រៀមខ្លួននិងយល់យ៉ាងច្បាស់អំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ និងត្រៀមខ្លួនចូលនៅក្នុងក្រុមបូជាចារ្យនាថ្ងៃអនាគត។ ទេវវិទ្យាល័យ ជាកន្លែងមួយដែលយើងដាំពូជនៃបូជាចារ្យ ដើម្បីចូលនៅក្នុងដីយ៉ាងជ្រៅនៃជីវិតជាមួយព្រះជាម្ចាស់។ គ្រាប់ពូជនេះ បន្តិចម្តងៗដុះឡើងរហូតក្លាយជាដើមឈើមួយយ៉ាងស្អាត គឺជាបូជាចារ្យមួយរូប។ ទេវវិទ្យាល័យ ជាកន្លែងមួយដែលយើងដាំមិនមែនសាបព្រោះទេ គឺយើងដាំពូជដែលយើងបានប្រមូលពីព្រះសហគមន៍នីមួយៗ។ ពីមួយថ្ងៃទៅមួយថ្ងៃ ជាមួយលោកនាយកទេវវិទ្យាល័យ ជាមួយលោកអភិបាល ជាមួយលោកបូជាចារ្យ ជាមួយបងប្អូនគ្រីស្តបរិស័ទ យើងរួមគ្នាថែរក្សាគ្រាប់ពូជនេះ ដើម្បីឲ្យបន្តិចម្តងៗលូតលាស់ដោយចាក់ឫសនៅក្នុងជីវិតនៃព្រះយេស៊ូគ្រីស្ត នៅក្នុងជីវិតនៃព្រះសហគមន៍ និងនៅក្នុងជីវិតនៃសង្គម។

បន្តិចម្តងៗ ជីវិតដែលយើងបានទទួលពីព្រះយេស៊ូយាងចូល នៅក្នុងព្រះសហគមន៍ នៅក្នុងសង្គម ដើម្បីទៅជាដើមឈើមួយរឹងមាំ នៅថ្ងៃអនាគតទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យចូលនៅក្នុងក្រុមបូជាចារ្យដើម្បីបម្រើព្រះសហគមន៍គឺបម្រើបងប្អូនទាំងអស់។ យើងបានចូលនៅក្នុងសួនមួយយ៉ាងធំ ដែលណែនាំឲ្យយើងនឹកឃើញស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ដែលបានបង្កើតទាំងផ្កា ទាំងដើមឈើ ទាំងជីវិត...។ សួននេះ យើងមានលោកឪពុកលីនិងបងប្អូនគ្រីស្តបរិស័ទនៅភ្នំពេញថ្មីនេះ កំពុងសាបព្រោះដើម្បីឲ្យព្រះសហគមន៍យើងអាចចាក់ឫសនៅលើទឹកដី

នេះ និងទៅប្រកាសដំណឹងល្អនៅតំបន់ជុំវិញដោយសហការជាមួយបងស្រី ជាមួយលោកបូជាចារ្យនានា។ យើងចាក់ឬសនៅក្នុងដីនៃជីវិតរបស់ព្រះសហគមន៍ ទាំងភូមិភាគ ទាំងព្រះសហគមន៍ផ្ទាល់ដែលកំពុងយាងចូលនៅក្នុងខ្លួននិស្សិតទេវ។ ទេវវិទ្យាល័យ ជាកន្លែងមួយដើម្បីរៀន ដើម្បីអធិដ្ឋាន ដើម្បីបង្កើតទំនាក់ទំនងជាមួយបងប្អូនទាំងអស់ ឲ្យឬសរបស់យើងចូលជ្រៅនៅក្នុងដីដើម្បីទៅរកប្រភពនៃជីវិត។ ប្រភពនៃជីវិតរបស់យើង គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលព្រះយេស៊ូឲ្យយើងប្រកាសជាឱឡារិក។

តួនាទីរបស់យើងជាបូជាចារ្យ ដែលប្រកាសដំណឹងល្អលើទឹកដីប្រទេសកម្ពុជា គឺប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ថ្ងៃនេះយើងមានពីរនាក់ គឺប៊ុនលី និងសំណាង ដែលទៅជាអ្នកអានប្រកាសដំណឹងល្អ មិនមែនតែអាននៅក្នុងអភិបូជាគឺជាអ្នកប្រកាសដំណឹងល្អតាមជីវិតផ្ទាល់ខ្លួន។ ឲ្យយើងប្រកាសដំណឹងល្អដែលមិនចេះអស់កម្លាំង ដើម្បីទៅប្រាប់ដំណឹងដ៏អស្ចារ្យនៃជីវិតដែលយើងទទួលពីព្រះយេស៊ូដល់បងប្អូនដែលមិនមែនជាគ្រីស្តបរិស័ទ។ យើងជាលោកអភិបាល យើងជាបូជាចារ្យ យើងជានិស្សិតទេវវិទ្យាល័យ យើងជាបងប្រុសបងស្រី យើងជាគ្រីស្តបរិស័ទដែលមិនចេះអស់កម្លាំងនៅក្នុងការប្រកាសដំណឹងល្អតាមរបៀបព្រះយេស៊ូ។ បន្ទាប់ពីព្រះយេស៊ូបានអប់រំគេហើយ ព្រះអង្គបានព្យាបាលគេឲ្យគេមានជីវិតដោយព្រះយេស៊ូប៉ះគេ មានន័យថាព្រះអង្គជិតស្និទ្ធជាមួយគេ និងម្យ៉ាងទៀតព្រះយេស៊ូមានព្រះបន្ទូលហើយអនុវត្តអ្វីដែលព្រះអង្គប្រាប់។ ព្រះយេស៊ូបានភ្ជាប់ជាមួយគេគឺស្នាដៃ សកម្មភាព និងព្រះយេស៊ូមានព្រះបន្ទូល។ ដូច្នេះ នៅពេលយើងប្រកាសដំណឹងល្អរបស់ព្រះយេស៊ូគ្រីស្តជាអម្ចាស់ យើងមិនតែនិយាយលើបបូរមាត់របស់យើងទេ ឲ្យយើងអនុវត្តតាមជីវិតរបស់យើងយ៉ាងជាក់ស្តែង។

នៅពេលយើងប្រកាសដំណឹងល្អដល់បងប្អូនឯទៀតៗ គឺណែនាំឲ្យគ្រីស្តបរិស័ទរបស់យើងយកព្រះបន្ទូលជាជីវិត។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាព្រះបន្ទូលដ៏មានជីវិតឲ្យយើងអានព្រះបន្ទូលរាល់ថ្ងៃ ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ចូលនៅក្នុងដួងចិត្តរបស់យើង។ ធ្វើដូចម្តេច ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងខ្លួនរបស់យើង និងឲ្យមានផ្លែសម្រាប់បងប្អូនឯទៀតៗ សម្រាប់ជីវិតរបស់យើង។ យើងដឹងថា ព្រះបន្ទូលនីមួយៗណែនាំឲ្យយើងភ្ញាក់ជានិច្ចដើម្បីទទួលជីវិតថ្មី និងដើម្បីចូលនៅក្នុងអំណរសប្បាយនៃការប្រកាសដំណឹងល្អ។

យើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានព្រះពរដល់និស្សិតទេវវិទ្យាល័យ ដល់លោកនាយកនិងលោកបូជាចារ្យដែលបង្រៀននៅទេវវិទ្យាល័យ ដើម្បីណែនាំឲ្យកូនសិស្សលោកអភិបាលទាំងអស់ គេអាចបន្តរៀបចំខ្លួនដើម្បីទៅជាកូនបូជាចារ្យដែលល្អតលាស់បន្តិចម្តងៗដើម្បីកោតសរសើរសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងដើម្បីទៅជាដើមឈើដែលពោរពេញដោយ

កន្លែងស្វាគមន៍គ្រប់បក្សាបក្សី និងឲ្យឫសចាក់យ៉ាងជ្រៅនៅក្នុងដីដើម្បីរកឃើញជីវិតដែលមកពីព្រះយេស៊ូផ្ទាល់។ អាម៉ែន៕